# ស្ថានភាពអតិផរណានៅខែសីហា ឆ្នាំ២០១៧

## ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែសីហា ឆ្នាំ២០១៧ កើនឡើងក្នុងអត្រា **០,៤%** ធៀបនឹងខែមុន និងកើនឡើង **២,៦%** ធៀបនឹង១២ខែមុន។

ក្នុងខែសីហានេះ សន្ទស្សន៍ថ្លៃនៃក្រុមទំនិញភាគច្រើនមានការកើនឡើងគួរឱ្យកត់សម្គាល់ធៀបនឹងខែកក្កដាកន្លងទៅ ជាពិសេសសន្ទស្សន៍ថ្លៃការដឹកជញ្ជូន កើនឡើង ១,៤% ដោយសារកំណើនថ្លៃប្រេងសាំងធម្មតា(៣,១%) និងម៉ាស៊ូត(១,១%)។ រីឯសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង សន្ទស្សន៍ថ្លៃសម្លៀកបំពាក់និងស្បែកជើង និងសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន ក៏បានកើនឡើងផងដែរដោយសារកំណើនឡើងថ្លៃអង្ករ(០,២%) សាច់(០,៧%) បន្លែ(១,១%) ប្រេងឆា(២,៦%) សម្លៀកបំពាក់(០,៩%) និងវត្ថុធាតុដើមសម្លៀកបំពាក់(១,៤%)។

បើធៀបនឹងខែដូចគ្នាឆ្នាំមុន សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ភាគច្រើនក៏មានកំណើនគួរកត់សម្គាល់ផងដែរ ដោយកំណើនថ្លៃក្រុមទំនិញមួយចំនួនហាក់មានការងើបឡើងវិញបន្ទាប់ពីមានកំណើនទាបនៅក្នុងកំឡុងខែមិថុនានិងកក្កដាកន្លងទៅ, ក្នុងនោះសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈគ្មានជាតិស្រវឹងបានកើនឡើង ២,៨% ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់បានកើន ១,៣% សម្លៀកបំពាក់និងស្បែកជើងបានកើន ៣,៥% និងការដឹកជញ្ជូនបានកើន ៤,២%។

តាមការធ្វើចំណោលគិតដល់ត្រឹមខែធ្នូ ឆ្នាំ២០១៧ អតិផរណាប្រចាំឆ្នាំ(year on year)អាចមានអត្រា ២,០% និងអតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចមានអត្រា ២,៩%។

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | ធៀបនឹងខែ | ធៀបនឹង១ឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **+០,៤** | **+២,៦** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | +០,៤ | +២,៨ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +០,២ | +១,៣ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | +០,៧ | +៣,៥ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈ | +០,២ | -០,៥ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការ | +០,១ | +១,១ |
| ៦-សុខាភិបាល | +០,៣ | +១,៣ |
| ៧-ការដឹកជញ្ជូន | +១,៤ | +៤,២ |
| ៨-គមនាគមន៍ | ០,០ | -០,២ |
| ៩-ការកំសាន្ត និងវប្បធម៌ | -០,៦ | +០,៦ |
| ១០-ការសិក្សា | ០,០ | ០,០ |
| ១១-ភោជនីយដ្ឋាន | +០,៧ | +៧,៣ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | +០,៦ | +០,៥ |

| តារាង ២÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ (%) | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបខែមុន | | | ធៀបនឹងឆ្នាំមុន | | |
| | ២០១៧ | | | ២០១៧ | | |
| | មិថុនា | កក្កដា | សីហា | មិថុនា | កក្កដា | សីហា |
| អង្ករ | +០,៧ | +០,២ | +០,២ | +២,៤ | +២,២ | +១,៩ |
| សាច់គោ | -០,៣ | +០,៣ | +១,២ | +១,៨ | +២,០ | +២,៤ |
| សាច់មាន់ | +០,៧ | +០,៤ | +១,១ | +១,៦ | +១,៩ | +២,៥ |
| សាច់ទា | -០,៤ | +០,៩ | +១,៤ | -១,២ | ០,០ | +១,៣ |
| សាច់ជ្រូក | -០,១ | +០,១ | +០,៣ | +១,៤ | +១,២ | +១,០ |
| ត្រីទឹកសាប និងត្រីទឹកសមុទ្រ | +០,៨ | +០,២ | +០,១ | +៥,៤ | +៤,៩ | +៤,៨ |
| ក្នុងនោះត្រីស្រស់ | +១,១ | +០,២ | -០,២ | +៦,០ | +៥,៤ | +៥,០ |
| ផ្លែឈើ | +០,៤ | +០,៩ | -០,៣ | +០,៦ | +១,៨ | +១,៥ |
| ផ្លែឈើស្រស់ | ០,០ | +១,២ | -០,៧ | +០,២ | +១,៨ | +១,១ |
| បន្លែ | -១,៨ | +១,៧ | +១,១ | +១,១ | +៣,២ | +៣,៦ |
| បន្លែជាស្លឹក | -២,១ | +២,៥ | +០,៨ | +០,៣ | +៤,០ | +៤,១ |
| បន្លែជាផ្លែ | -២,៧ | +១,២ | +២,៣ | -១,៤ | +០,២ | +១,៤ |

## ១/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាប្រចាំឆ្នាំ (គិតជា %) | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេស | ២០១៦ | | | | | | | ២០១៧ | | | | | | |
| | កុម្ភៈ | មីនា | មេ | ឧសភា | មិថុនា | កក្កដា | សីហា | កុម្ភៈ | មីនា | មេ | ឧសភា | មិថុនា | កក្កដា | សីហា |
| ប្រទេសកម្ពុជា | 2.3 | 2.0 | 2.8 | 3.2 | 3.3 | 3.0 | 2.9 | 4.0 | 4.3 | 3.2 | 2.5 | 2.3 | 2.3 | 2.6 |
| ប្រទេសវៀតណាម | 1.3 | 1.7 | 1.9 | 2.3 | 2.4 | 2.4 | 2.6 | 5.0 | 4.7 | 4.3 | 3.2 | 2.5 | 2.5 | 3.4 |
| ប្រទេសថៃ | -0.5 | -0.5 | 0.1 | 0.5 | 0.4 | 0.1 | 0.3 | 1.4 | 0.8 | 0.4 | -0.04 | -0.05 | 0.2 | 0.3 |
| ប្រទេសម៉ាឡេស៊ី | 4.2 | 2.6 | 2.1 | 2.1 | 1.6 | 1.1 | 1.5 | 4.5 | 5.1 | 4.4 | 3.9 | 3.6 | 3.2 | 3.7 |
| ប្រទេសឥណ្ឌូនេស៊ី | 4.4 | 4.5 | 3.6 | 3.3 | 3.5 | 3.2 | 2.8 | 3.8 | 3.6 | 4.2 | 4.3 | 4.4 | 3.9 | 3.8 |
| ប្រទេសហ្វីលីពីន | 0.9 | 1.1 | 1.1 | 1.6 | 1.9 | 1.9 | 1.8 | 3.3 | 3.4 | 3.4 | 3.1 | 2.7 | 2.8 | 3.1 |
| ប្រទេសចិន | 2.3 | 2.3 | 2.3 | 2.0 | 1.9 | 1.8 | 1.3 | 0.8 | 0.9 | 1.2 | 1.5 | 1.5 | 1.4 | 1.8 |
| ប្រទេសកូរ៉េខាងត្បូង | 1.2 | 0.97 | 1.0 | 0.8 | 0.8 | 0.8 | 0.4 | 1.9 | 2.2 | 1.9 | 2.0 | 1.9 | 2.2 | 2.6 |
| ប្រទេសជប៉ុន | 0.3 | 0.0 | -0.3 | -0.5 | -0.4 | -0.4 | -0.5 | 0.3 | 0.2 | 0.4 | 0.4 | 0.4 | 0.4 | 0.7 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត ពីគេហទំព័រ http://www.tradingeconomics.com;

**<u>កំណត់សម្គាល់</u>**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្រ្ត (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ***

***ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***